ខាលីគ្រាន់តែចង់បានមិត្តម្នាក់ប៉ុណ្ណោះ ។

អាហារថ្ងៃត្រង់ដ៏ឯកោ

ដោយ ស្តេស៊ី លីន ឃែរ៉ូល

(ផ្អែកទៅលើដំណើររឿងពិត)

« *ព្រះវិញ្ញាណបរិសុទ្ធខ្សឹបដោយសំឡេងតូចរហៀង* »
(សៀវភៅចម្រៀងកុមារ *ទំព័រ ៥៦*) ។

ខាលីបានដើរទៅបន្ទប់អាហារ ហើយមើលជុំវិញ ។ ក្មេងៗផ្សេងទៀតទាំងអស់រត់តម្រង់ទៅមិត្តភក្តិរបស់ពួកគេ ហើយបានប្រមូលផ្តុំគ្នានៅតុ ។ បន្ទប់នោះអ៊ូអរដោយមានសម្លេងរំភើប និងសំណើចដ៏រីករាយ ។ វាទើបតែជាថ្ងៃទីពីរនៅសាលា ប៉ុន្តែវាហាក់ដូចជាគ្រប់គ្នាមាននរណាម្នាក់ដើម្បីអង្គុយជាមួយរួចទៅហើយ លើកលែងតែខាលី ។

នាងបានច្របាច់ដៃកាបូបអាហាររបស់នាង ហើយបានដើរទៅកាន់តុមួយ ។ « តើខ្ញុំអាចអង្គុយនៅក្បែរឯងបានទេ ? » ខាលីបានសួរ ។

ក្មេងស្រីម្នាក់មានសក់ក្រងវែងពណ៌ត្នោតបានសម្លឹងមើលមក ។ នាងបានច្រឡេត ហើយគ្រវីក្បាលរបស់នាង ។ នាងបាននិយាយថា « អត់ទេ ។ មានអ្នកអង្គុយហើយ » ។

« មិនអីទេ ! » ខាលីបានខិតទៅកន្លែងអង្គុយទំនេរមួយទៀត ហើយបានអង្គុយចុះជាមួយនឹងកាបូបអាហាររបស់នាង ។

« ឯងមិនអាចអង្គុយទីនេះបានទេ ! « ខ្ញុំទុកកន្លែងអង្គុយហ្នឹងហើយ » ក្មេងប្រុសម្នាក់ពាក់អាវឆ្នូតពណ៌បៃតងបាននិយាយ ។ គេបានរុញកាបូបអាហាររបស់ខាលីទៅក្រោម ។ មិត្តគេទាំងអស់គ្នាបានសើច ។

ខាលីបានឱនចុះទៅរើសកាបូបអាហាររបស់នាងម្តងទៀត ។ នាងបានដើរទៅផ្នែកម្ខាងទៀតនៃបន្ទប់អាហារ ហើយអង្គុយនៅនឹងតុទំនេរមួយ ។ នាងបានឃើញក្មេងម្នាក់មកពីសហគមន៍នាង ហើយបានព្យាយាមគ្រវីដៃ ប៉ុន្តែគេបានសម្លឹងទៅម្ខាងទៀត ។ ខាលីបានជ្រួញចិញ្ចើម ។ ហេតុអ្វីគ្មាននរណាម្នាក់ចង់ធ្វើជាមិត្តរបស់នាង ?

ខាលីបានឈ្ងោកមុខមើលទៅស្បែកជើងរបស់នាង ។ នាងមិនមានអារម្មណ៍ចង់ញុំាទៀតទេ ។ នាងបានជូតភ្នែកនាង បិទកាបូបអាហាររបស់នាង ហើយបានដើរទៅខាងក្រៅ ។

គ្រប់គ្នាកំពុងលេងជាមួយមិត្តភ្ក្តិពួកគេទៅហើយ ។ ខាលីបានអង្គុយតែម្នាក់ឯងនៅលើកៅអីវែង ហើយបានមើលក្មេងផ្សេងទៀតលេងសប្បាយដោយគ្មានរូបនាង ។



រចនារូបភាពដោយ បាបារ៉ា បុនហ្វីនី



បន្ទាប់មកខាលីបានសម្គាល់ឃើញក្មេងប្រុសម្នាក់អាយុប្រហែលនាង កំពុងអង្គុយម្នាក់ឯងនៅលើស្មៅ ។ គេពាក់អាវដែលមានស្នាមប្រឡាក់ពណ៌លឿង ហើយសក់គេបះទៅក្រោយ ។

ខាលីបានបែរមុខចេញ ។ នាងបានឃើញក្មេងស្រីមួយក្រុមមកពីថ្នាក់នាងកំពុងលេងបោះបាល់ទៅវិញទៅមក ។ នាងពិតជាចង់ឲ្យពួកគេអញ្ជើញនាងឲ្យលេងជាមួយពួកគេណាស់ ។

ខាលីបានក្រឡេកមើលទៅក្មេងប្រុសនោះម្តងទៀត ។ គេឱនក្បាលចុះ ហើយកំពុងបោចស្មៅនៅនឹងជើងរបស់គេ ។ ខាលីបានចងចាំពីអ្វីមួយដែលម្តាយនាងបាននិយាយនៅពេលខ្លះ ៖ *រកមើលក្មេងៗដែលឯកា* ។

ខាលីបានជ្រួញចិញ្ចើម ។ *នាង*ក៏ឯកាដែរ ។ គ្មាននរណាម្នាក់ព្យាយាមធ្វើជាមិត្ត*របស់នាង*ទេ !

ប៉ុន្តែ បន្ទាប់មកខាលីបានគិតអំពីពេលដែលនាងបានទទួលបុណ្យជ្រមុជទឹកកាលពីឆ្នាំមុន ។ នាងបានសន្យាថានឹងស្តាប់ព្រះវិញ្ញាណបរិសុទ្ធ ។ ប្រហែលជាព្រះវិញ្ញាណបរិសុទ្ធបានជួយនាងឲ្យចងចាំនូវអ្វីដែលម្តាយនាងបានប្រាប់ ។ ប្រហែលជាព្រះវិញ្ញាណបរិសុទ្ធកំពុងព្យាយាមប្រាប់នាងឲ្យលេងជាមួយក្មេងប្រុសពាក់អាវពណ៌លឿងនោះ ។

ខាលីដកដង្ហើមធំ ហើយបានក្រោកឈរឡើង ។ អារម្មណ៍ដ៏កក់ក្តៅមួយជ្រាបក្នុងចិត្តរបស់នាង ។ នាងបានដើរទៅ ហើយបានអង្គុយជិតក្មេងប្រុសនោះនៅលើស្មៅ ។

នាងបាននិយាយថា « សួស្តី » ។

គាត់បាននិយាយរហឹមៗតបវិញថា « សួស្តី » ។

« តើឯងចូលចិត្តពណ៌អ្វីជាងគេ ? »

« អើ . . .បៃតង » ។

ខាលីបាននិយាយថា « ល្អណាស់ ។ ខ្ញុំចូលចិត្តពណ៌ផ្កាឈូក » ។ « តើឯងមានសត្វមួយដែលឯងចូលចិត្តទេ ? »

ក្មេងប្រុសនោះបានតម្រង់ខ្លួនបន្តិច ហើយបានសម្លឹងមើលនាង ។ « មែនហើយ ។ ខ្ញុំចូលចិត្តសត្វដាយណូស័រណាស់ » ។

« អូ ខ្ញុំក៏អញ្ចឹងដែរ ។ ខ្ញុំចូលចិត្តត្រៃសេរ៉ាថបស៍ជាងគេ » ។

ក្មេងប្រុសនោះបានញញឹម ។

ហើយកណ្តឹងក៏បានរោទិ៍ឡើង ។ ខាលីបានក្រោកឈរឡើង ហើយបានគ្រវីដៃលាទៅក្មេងប្រុសនោះ ។ នាងបានញញឹម កាលដែលនាងបានដើរត្រឡប់ទៅថ្នាក់រៀននាងវិញតែម្នាក់ឯង ។ នាងអាចនឹងមិនមានមិត្តល្អបំផុតម្នាក់ ប៉ុន្តែនាងបានមានអារម្មណ៍សប្បាយរីករាយ ដោយដឹងថា នាងបានធ្វើឲ្យម៉ោងចេញលេងរបស់មនុស្សម្នាក់បានប្រសើរឡើងបន្តិច ។ ●

អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។





ខ្ញុំប្រញាប់ទៅសាលា ។ ប៉ុន្តែ ខ្ញុំបានមានអារម្មណ៍ថា ខ្ញុំគួរតែយកដំឡូងចៀនមួយកញ្ចប់ពីផ្ទះសិន ។ បន្ទាប់ពីអាហារថ្ងៃត្រង់ហើយ ជ្រូ មិត្តរបស់ខ្ញុំមើលទៅដូចជាសោកសៅ ។ ខ្ញុំបានសួរគាត់ថាតើមានរឿងអ្វី ។ គាត់បានប្រាប់ថា គាត់ភ្លេចយកអាហារថ្ងៃត្រង់របស់គាត់មក ។ ខ្ញុំនឹកឃើញពីដំឡូងចៀនរបស់ខ្ញុំ ដូច្នេះខ្ញុំបានឲ្យទៅគាត់ ។ ជ្រូបាននិយាយថា « នោះជារឿងដ៏ល្អបំផុតដែលមនុស្សម្នាក់បានធ្វើសម្រាប់ខ្ញុំនៅសាលា » ។

ឡូរ៉ាំ អិម អាយុ ១១ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា